ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខាធិការដ្ឋាន

លេខ៖ ..០៧៦..ស..ជ..ណ.../គ.ជ.អ.ប.

# សេចក្តីជូនដំណឹង

## ស្តីពីការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាថ្មីរបស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)

**យោង** ៖ ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប. ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៥ លើលិខិតលេខ ០២១ ល.ស/គ.ជ.អ.ប. ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ របស់លេខាធិការដ្ឋាន គ.ជ.អ.ប.។

**លេខាធិការដ្ឋាន គ.ជ.អ.ប.** មានកិត្តិយសសូមគោរពជម្រាបជូនឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាធារណជនឱ្យបានជ្រាបថា៖ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) បានកែសម្រួលនិមិត្តសញ្ញាថ្មីរបស់ គ.ជ.អ.ប. ឱ្យមានលក្ខណៈសមស្របទៅនឹងចក្ខុវិស័យ និងបេសកកម្មរបស់ គ.ជ.អ.ប. ក្នុងការរៀបចំ និងអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក៏ដូចជាអាចធ្វើឱ្យក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងសាធារណជនមានភាពងាយស្រួលក្នុងការកត់សម្គាល់ ចងចាំ និងជឿជាក់លើ គ.ជ.អ.ប.។

ទន្ទឹមគ្នានេះ និមិត្តសញ្ញាថ្មីរបស់ គ.ជ.អ.ប. ត្រូវបានពិនិត្យ សម្រេច និងឯកភាពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** លើការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៥។ ក្នុងន័យនេះ ដើម្បីផ្លាស់ប្តូរនិមិត្តសញ្ញាចាស់បច្ចុប្បន្ន និងអាចប្រើប្រាស់នូវនិមិត្តសញ្ញាថ្មីក្នុងចរន្តការងាររបស់ គ.ជ.អ.ប. និងជៀសវាងការយល់ច្រឡំពីគ្រប់ភាគីពាក់ព័ន្ធ និងសាធារណជនទូទៅ លេខាធិការដ្ឋាន គ.ជ.អ.ប. សូមជូនដំណឹងការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវនិមិត្តសញ្ញាថ្មីរបស់ គ.ជ.អ.ប. ជំនួសនិមិត្តសញ្ញាចាស់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

សូមគោរពជូនភ្ជាប់នូវឧបសម្ព័ន្ធស្តីពីអត្ថន័យនៃនិមិត្តសញ្ញាថ្មីរបស់ គ.ជ.អ.ប.។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាធារណជន** មេត្តាជ្រាបជាព័ត៌មាន៕B

ថ្ងៃព្រហស្បតិ៍ ៩ រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០២៥

**រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ**
**និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.**

**ចាន់ សុធា**

**ឧបសម្ព័ន្ធនៃនិមិត្តសញ្ញាថ្មីរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ**

**តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)**

## អត្ថន័យ

- **អត្ថន័យរួមនៃនិមិត្តសញ្ញា៖** គ.ជ.អ.ប. ជាស្ថាប័នអន្តរក្រសួងដែលជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំ សម្របសម្រួលលើការរៀបចំ និងអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយមានការចូលរួមពីក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព យុត្តិធម៌ បរិយាបន្ន និងសមធម៌សង្គម ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងរួមចំណែកកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័ស។
- **ពណ៌ស៖** តំណាងឱ្យតម្លាភាព សុចរិតភាព គណនេយ្យភាព ភាពស្អាតស្អំ ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ការទទួលខុសត្រូវខ្ពស់ និងការអំណត់ព្យាយាមក្នុងការបំពេញតួនាទី ភារកិច្ចដើម្បីបម្រើជាតិមាតុភូមិ។
- **ពណ៌ខៀវ៖** តំណាងឱ្យសុខសន្តិភាព សិទ្ធិសេរីភាព ការអភិវឌ្ឍ បរិយាបន្ន និងសមធម៌សង្គមក្នុងក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។
- **រូបជើងពានទ្រសៀវភៅ៖** តំណាងឱ្យបេសកកម្មរបស់ គ.ជ.អ.ប. ក្នុងការរៀបចំតាក់តែងកម្មវិធីជាតិ ផែនការអនុវត្ត ការលើកអនុសាសន៍ជូនរាជរដ្ឋាភិបាល និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន

ពាក់ព័ន្ធក្នុងការរៀបចំតាក់តែង ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត នានា កម្មវិធី ផែនការសកម្មភាពពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ សំដៅធានាប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។

- **គ.ជ.អ.ប.**៖ មានន័យថា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- **រូបផ្ការំដួល**៖ ជាប្រភេទផ្កាតំណាងឱ្យអត្តសញ្ញាណរបស់ប្រទេសកម្ពុជាដែលមានក្លិនក្រអូបសព្វសាយប្រៀបដូចទៅនឹងចក្ខុវិស័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែល្អប្រសើរឡើង ប្រកបដោយតម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម ស្របតាមបរិបទនៃប្រទេសកម្ពុជា (កត្តានយោបាយ ភូមិសាស្ត្រ ប្រជាសាស្ត្រ សេដ្ឋកិច្ច វប្បធម៌ និងប្រពៃណីជាតិ)។ **ក្លិនផ្ការំដួល**៖ ជំនឿទុកចិត្តនិងភាពពេញចិត្តពីគ្រប់ភាគីពាក់ព័ន្ធក្នុងការចូលរួមអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា។ **សម្រស់ផ្ការំដួល**៖ការរៀបចំស្ថាប័នដែលមានលក្ខណៈធន់មាំ ទំនើប ស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ **គុណតម្លៃផ្ការំដួល**៖ ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈនិងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព គុណភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។
- **អដ្ឋរង្សី ៨ឆ្នូត**៖ តំណាងឱ្យគោលការណ៍គ្រឹះទាំង៨នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលបានកំណត់ក្នុងមាត្រា១២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួមមាន៖ ១. ភាពជាតំណាងសាធារណៈ ២. ស្វ័យភាពរបស់មូលដ្ឋាន ៣. ការពិគ្រោះយោបល់ និងការចូលរួម ៤. ការឆ្លើយតប និងគណនេយ្យភាព ៥. ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន ៦. ការលើកស្ទួយសមធម៌ ៧. តម្លាភាព និងសុចរិតភាព ៨. វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។